# សុន្ទរកថាស្វាគមន៍
# របស់លោក ឈិត សំអាត នាយកប្រតិបត្តិ
# វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
# សិក្ខាសាលាស្តីពី ជនជាតិដើមភាគតិច
# និងការប្រើប្រាស់ដីធ្លីសហគមន៍ក្នុងប្រទេសកម្ពុជា

*នៅថ្ងៃទី ០៧ ដល់ ០៨ ខែកុម្ភៈ ឆ្នាំ២០០៧ នៅសណ្ឋាគារសាន់វេ ភ្នំពេញ*

- សូមគោរព ឯកឧត្តម **ជា សុផារ៉ា** រដ្ឋលេខាធិកានៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងឱកាសនេះ ជាទីគោរព !
- សូមគោរព ឯកឧត្តម-លោកជំទាវ និងលោក-លោកស្រីដែលអញ្ជើញមកពីក្រសួង នាយកដ្ឋាន និងមន្ទីរពាក់ពន្ធ័នានា ជាទីគោរព!
- សូមគោរព លោក-លោកស្រីជាតំណាងអង្គការជាតិ និងអង្គការអន្តរជាតិ ជាគោរពរាប់អាន!
- លោក-លោកស្រីតំណាងជនជាតិដើមភាគតិចមកពីខេត្តនានាក្នុងប្រទេសកម្ពុជា ជាទីស្នេហា!

តាងនាមឱ្យ វេទិកា នៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដែលបានចូលរួមចែករំលែក ការយល់ដឹងមួយចំនួនក្នុងសិក្ខាសាលាស្តីពី **ជនជាតិដើមភាគតិច និងការប្រើប្រាស់ដីធ្លីសហគមន៍ក្នុងប្រទេសកម្ពុជា** ។ ជំនួសមុខឱ្យគណៈកម្មាការរៀបចំ ដែលមាន វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងអង្គការពលកម្មអន្តរជាតិ ខ្ញុំសូមថ្លែងអំណរគុណ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ ឯកឧត្តម **ជា សុផារ៉ា** ដែលជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមប្រឹក្សា គោលនយោបាយដីធ្លី អ្នករាយការណ៍ពិសេសនៃអង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់ជនជាតិដើមភាគតិច - ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងនាងកញ្ញាទាំងអស់ដែលមានវត្តមាននាថ្ងៃនេះ។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី

នៅក្នុងព្រះរាជាណាកម្ពុជារបស់យើង មានជនជាតិដើម ភាគតិចប្រមាណ ១៧ក្រុមដែលរស់នៅតំបន់ខ្ពង់រាបដែលមានព្រៃក្រាស់ៗដូចជាខេត្ត រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ក្រចេះ ព្រះវិហារ និងកំពង់ធំ ជាដើម ដែលមានចំនួនប្រមាណ ១,៥ ភាគរយ នៃប្រជាជនសរុបដែលរស់នៅពឹងផ្អែកទាំងស្រុងលើធនធានធម្មជាតិ

សំរាប់ការប្រើប្រាស់ជាប្រពៃណី និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។ ប៉ុន្តែយើងសង្កេតឃើញថាធនធានធម្មជាតិរបស់សហគន៍ ត្រូវបាននិងកំពុងប្រឈមមុខនឹងការបាត់បង់សិទ្ធិកាន់កាប់ បណ្តាលមកពីអ្នកមាន និងអ្នកមានអំណាចមួយចំនួន និងការផ្តល់ដីសម្បទានសេដ្ឋកិច្ចពុំមានការប្រឹក្សាយោបល់ជាមួយសហគមន៍ដែលជាការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះយើងទាំងអស់គ្នា។ តាមការសិក្សារបស់អង្គការវេទិការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា រកឃើញថា ពីខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ខែមករា ឆ្នាំ២០០៦ សហគមន៍ជនជាតិដើមភាគតិចបាត់បង់សិទ្ធិកាន់កាប់ដីធ្លីប្រមាណ ៣០ភាគរយនៃផ្ទៃដីសរុប របស់សហគមន៍។ បញ្ហានេះបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គមរស់នៅ វប្បធម៌ សន្តិសុខស្បៀង និងបរិស្ថាន របស់សហគមន៍ជនជាតិដើមភាគតិច។ លើសពីនេះទៀត ការបាត់បង់កម្មសិទ្ធិដីធ្លី សហគមន៍ជនជាតិដើមភាគតិចដូចជា ព្រៃអារក្ស ដីព្រៃកប់ខ្មោច ដីចំការវិលជុំ ដីបម្រុងទុក ដីប្រភពទឹក ព្រៃឬស្សី និងដីគង្វាលសត្វ ជាដើម ដែលបានបង្កឱ្យមានអសន្តិសុខ ការផ្លាស់ប្តូរប្រពៃណីជំនឿ និងបាត់បង់បន្តិចម្តងៗ នូវសេចក្តីថ្លៃថ្នូរ សាមគ្គីភាព អត្តសញ្ញាណ និងការគ្រប់គ្រងតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។ លើសពីនេះទៅទៀតសហគមន៍ពុំទាន់យល់ច្បាស់អំពីគោលនយោបាយ និងច្បាប់នានាដែលធានាដល់សិទ្ធិរបស់គាត់។

ដើម្បីឆ្លើយតបនៅនឹងបញ្ហា និងការព្រួយបារម្ភទាំងអស់នេះ វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងអង្គការពលកម្មអន្តរជាតិបានរៀបចំសិក្ខាសាលានេះឡើងក្នុងគោលបំណង :

- ពិភាក្សាគ្នាដោយចំហអំពីបញ្ហាទាំងឡាយដែលប៉ះពាល់ក្នុងការប្រើប្រាស់ដីធ្លីសហគមន៍ជនជាតិដើមភាគតិច និងប្រភពនៃការប្រកបរបរចិញ្ចឹមជីវិតដូចជា ការបាត់បង់កម្មសិទ្ធិដីធ្លីតាមរយៈការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងការបោកបញ្ឆោតយកដីសហគមន៍
- រិះរកកិច្ចព្រមព្រៀងដែលទាក់ទិននឹងការអនុវត្តជាក់ស្តែងលើការប្រើប្រាស់ដីធ្លីរបស់ជនជាតិដើមភាគតិច
- សម្រេចឱ្យបាននូវការប្តេជ្ញាចិត្ត និងសំណើឱ្យមានការចាត់វិធានការច្បាស់លាស់សម្រាប់ការពារសិទ្ធិជនជាតិដើមភាគតិចលើដីធ្លីដែលកំពុងត្រៀមចុះប័ណ្ណកម្មសិទ្ធិសមូហភាពសហគមន៍។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី

ទន្ទឹមគ្នានេះដែរ យើងឃើញរាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់ចំពោះបញ្ហា ដោយមានការដាក់ចេញនូវកម្មវិធី កំណែទម្រង់ ជាច្រើនផ្នែកដូចជា កំណែទម្រង់ដីធ្លី និងព្រៃឈើ ដែលត្រូវបានចាត់ទុកជាបញ្ហាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុវត្ថិភាពដីធ្លីរបស់សហគមន៍ ពីការរំលោភបំពានរបស់ជនឱកាសនិយមមួយចំនួន។ ឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃគោលនយោបាយដីធ្លី ឆ្នាំ២០០២ ក៏បានលើកឡើងអំពីលក្ខណៈពិសេស ខាងសង្គមលើការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ជនជាតិដើម ភាគតិចដែលប្រឈមមុខ

នឹងបញ្ហាជាញឹកញាប់។ ច្បាប់ភូមិបាល ឆ្នាំ២០០១ បានទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា ក្នុងការកាន់កាប់អចលនវត្ថុ របស់ខ្លួនជាកម្មសិទ្ធិសមូហភាព និងប្រើប្រាស់ដីធ្លីតាមទំនៀមទម្លាប់ ប្រពៃណី។

ស្របតាមកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល យើងទាំងអស់គ្នា សង្គមស៊ីវិល និងតំណាងជនជាតិដើមភាគតិច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាដីធ្លី បានបង្កើតផែនការអភិវឌ្ឍន៍ និងយន្តការមួយចំនួនដូចជា ការត្រៀមចុះបញ្ជីដីមដើម្បីផ្តល់ ប័ណ្ណកម្មសិទ្ធិសមូហភាពជូនសហគមន៍ និងការរៀបចំគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច ជាដើម។ ដោយឡែកគោលនយោបាយ យន្តការ និងផែនការទាំងអស់នេះហាក់ដូចមិនទាន់បានដំណើរការពេញលេញ ដើម្បីបំពេញតម្រូវការរបស់សហគមន៍ជនជាតិដើមភាគតិចនៅឡើយ។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី

ឆ្លៀតឱកាសក្នុងពេលនេះ យើងខ្ញុំសូមសំនូមពរដល់រាជរដ្ឋាភិបាលមេត្តាបន្តចាត់វិធានការម៉ឺងម៉ាត់ និងជំរុញឱ្យ មានការអនុវត្ត ច្បាប់ភូមិបាល ២០០១ និង រដ្ឋាភិបាលកម្ពុជាត្រូវប្រកាស់បញ្ឈប់ការលក់-ដូរដី និងការចេញបណ្ណ័ភោគៈដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច ជាពិសេស ក្នុងការរង់ចាំដំណើរការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច និងពន្លឿនការចុះបញ្ជីដីសមូហភាពរបស់ជនជាតិដើមភាគតិច។

ជាថ្មីម្តងទៀត តាងនាមវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមធ្វើការកោតសរសើរដល់ស្មារតីយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលដែលគាំទ្រ និងចូលរួមការពារសិទ្ធិជនជាតិដើមភាគតិច ហើយអង្គការមិនមែនរដ្ឋាភិបាល សូមប្តេជ្ញាធ្វើការសហការជាមួយស្ថាប័នពាក់ពន្ធ័នានាសម្រាប់បង្កើត និងអនុវត្តគោលនយោបាយជនជាតិដើមភាគតិចឱ្យមានប្រសិទ្ធភាព ដូចជាការគោរពសិទ្ធិ អត្តសញ្ញាណ វប្បធម៌ និងរបៀបរស់ នៅរបស់ជនជាតិដើម ភាគតិចដើម្បីឈានទៅរកការកាត់បន្ថយភាពក្រីក្រ។

សូមថ្លែងអំណរគុណដល់វេទិកា នៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ការិយាល័យឧត្តម ស្នងការអង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងអង្គការពលកម្មអន្តរជាតិដែលបានឧបត្ថម្ភសិក្ខាសាលា ហើយសូមថ្លែងអំណរគុណដល់អង្គការសមាជិកទាំងអស់ ដែលបានសហការរៀបចំសិក្ខាសាលានេះប្រកបដោយជោគជ័យ។ សូមជូនពរឱ្យសិក្ខាសាលារយៈពីរថ្ងៃនេះប្រកបដោយការពិភាក្សាយ៉ាងផុសផុល និងផ្លែផ្កា។

ចុងបញ្ចប់ សូមគោរពជូនពរ គណធិបតី ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងនាងកញ្ញាទាំងអស់ឱ្យជួបប្រទះ ពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈកុំបីឃ្លាងឃ្លាតឡើយ។

**សូមអរគុណ !**